**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
១០៩២/១៧-១២-២០១០
សាលដីកា
លេខ: ៧១ ក្រ ប ស
ចុះថ្ងៃទី ២០-៦-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ១១-៦-២០១២ ដែលមានសមាសភាពដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ១០៩២ ចុះថ្ងៃទី ១៧-១២-២០១០ របស់សាលាឧទ្ធរណ៍ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ជាន ហៅ ផាត ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចារ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃផ្ទះជួល [redacted] មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធគ្មាន ទោសពីមុនគ្មាន។ ចាប់ខ្លួននៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០៨ ។

២-ជនជាប់ចោទឈ្មោះ [redacted] រ៉ាវី ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃស្នួល ឃុំវៀង ស្រុកព្រៃអំពិល ខេត្តតាកែវ ទីលំនៅសព្វថ្ងៃភូមិ [redacted] មុខរបរកសិករ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។

៣-ជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារ៉ា ហៅ រដ្ឋ ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអន្លង់ក្រសេក ឃុំព្រៃអំពិល ស្រុកស្អាង ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃផ្ទះគ្មានលេខ [redacted] មុខរបរកម្មករ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted]

[redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។

៤-ជនជាប់ចោទឈ្មោះ [redacted] រ៉ាឌី ហៅ គ្រេន ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ ព្រែកសំរោង ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃ [redacted] មុខរបរសិស្ស ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។

ជាប់ចោទពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភ្នំពេញ កាលពីឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៥-ជនជាប់ចោទឈ្មោះ [redacted] ភ័ស្ត ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃ [redacted] មុខរបរ ធ្វើស្រែ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០៨ ។

៦-ជនជាប់ចោទឈ្មោះ [redacted] វណ្ណី ភេទប្រុស អាយុ ២៦ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃ [redacted] មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។

៧-ជនជាប់ចោទឈ្មោះ [redacted] ពុទ្ធា ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ ៣ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃ [redacted] មុខរបរអង្គរក្ស ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ។ ចាប់ខ្លួននៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។

៨-ជនជាប់ចោទឈ្មោះ [redacted] រ៉ា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃភូមិចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ មុខរបរនៅផ្ទះ ឪពុកឈ្មោះ [redacted] ចំរើន (រ) ម្តាយឈ្មោះ [redacted] រីណា (រ) ។ ចាប់ខ្លួននៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។

៩-ជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចារ ឃុំចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃភូមិចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ មុខរបរនៅផ្ទះ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨

១០-ជនជាប់ចោទឈ្មោះ [redacted] ចាន់ណារ័ត្ន ភេទប្រុស អាយុ ១៩ឆ្នាំ កើតនៅភូមិចារ ឃុំចារ ស្រុកព្រែកប្បាស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃ [redacted] ភ្នំពេញ មុខរបរលក់ត្រី ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៨ ។ល។



Scanned with CamScanner

-ជាប់ចោទពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**៦រឿងហេតុមានដូចតទៅ**

**សកម្មភាព** ប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ ៖

នៅក្នុងឆ្នាំ ២០០៧ ជនជាប់ចោទឈ្មោះ [redacted] ផាន.ឈ្មោះ [redacted] ភ៉ារី ,ឈ្មោះ [redacted] ប៊ុណ្ណារ៉ា ហៅ រដ្ឋ និងឈ្មោះ [redacted] រ៉ាឌី ពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូពីជនរងគ្រោះនៅមុំដើមពោធិ៍វិមានឯករាជ្យ មុំផ្សារកណ្តាល និងនៅផ្សារស៊ីឡឹប ដោយប្រើកាំភ្លើងម៉ាក K៥៩ ប្រាកដមែន។ កាំភ្លើង K៥៩ នេះ ជនជាប់ចោទទាំងបួននាក់ ពិតជាបានយកទៅប្រើប្រាស់ដោយខុសច្បាប់ ហើយប្លន់យកម៉ូតូពីជនរងគ្រោះប្រាកដមែន ហើយម៉ូតូដែលប្លន់បានទៅ ជនជាប់ចោទខាងលើបានយកទៅលក់ឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណី ហៅ ខ្លី ឈ្មោះ [redacted] ចាន់ណារ័ត្ន ឈ្មោះ [redacted] ពុទ្ធា ឈ្មោះ [redacted] ភ័ស្ត ឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted] រ៉ា ប្រាកដមែន។

**បានឃើញ**សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីតាមសាលក្រមព្រហ្មទណ្ឌលេខ: ៤៧ (ក្រ.៤) ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០០៨ សម្រេចថា:

១-ផ្តន្ទាទោសជនជាប់ចោទ៖

ក-ឈ្មោះ [redacted] ផាន ហៅ ផាត ភេទប្រុស អាយុ ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ (ប្រាំពីរឆ្នាំ) គិតបន្តពីសាលក្រមលេខ ៤១ កប.៣ ចុះថ្ងៃទី ២១-០៤-២០០៨

ខ-ឈ្មោះ [redacted] ភ៉ារី ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ (ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧

គ-ឈ្មោះ [redacted] ប៊ុណ្ណារ៉ា ហៅ រដ្ឋ ភេទប្រុស អាយុ ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ (ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៧

ឃ-ឈ្មោះ [redacted] រ៉ាឌី ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ (បួនឆ្នាំ) គិតបន្តពីសាលក្រមលេខ ៤១ កប.៣ ចុះថ្ងៃទី ២១-០៤-២០០៨ យោងអនុសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ។

ពិន័យជាប្រាក់ម្នាក់ៗ ៥០ម៉ឺនរៀល (ហាសិបម៉ឺនរៀល) ចូលរដ្ឋចាប់ពីថ្ងៃសាលក្រមស្ថាពរតទៅ។

ពីបទ: ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភ្នំពេញ កាលពីឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

២-ផ្តន្ទាទោសជនជាប់ចោទ:

ក-ឈ្មោះ [redacted] វណ្ណី ភេទប្រុស អាយុ ២៦ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២៩-១២-២០០៧ តែទោសអនុវត្តពន្ធនាគារ ០៨ ខែ (ប្រាំបីខែ) នៅសល់ពីនេះព្យួរក្នុងរយៈពេលសាកល្បង ០៥ ឆ្នាំ ។

ខ-ឈ្មោះ [redacted] ពុទ្ធា ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២៩-១២-២០០៧ តែទោសអនុវត្តពន្ធនាគារ ០៨ ខែ (ប្រាំបីខែ) នៅសល់ពីនេះព្យួរក្នុងរយៈពេលសាកល្បង ០៥ ឆ្នាំ ។

គ-ឈ្មោះ [redacted] ភ័ស្ត ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ២៩-១២-២០០៧ តែទោសអនុវត្តពន្ធនាគារ ០៨ ខែ (ប្រាំបីខែ) នៅសល់ពីនេះព្យួរក្នុងរយៈពេលសាកល្បង ០៥ ឆ្នាំ ។



Scanned with CamScanner

ឃ-ឈ្មោះ [redacted] ចាន់ណារ័ត្ត ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២៩-១២-២០០៧ តែទោសនេះត្រូវព្យួរទាំងអស់ក្នុងរយៈពេលសាកល្បង ៥ឆ្នាំ។

ង-ឈ្មោះ [redacted] ៣៧ ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) តែទោសនេះត្រូវព្យួរទាំងអស់ ក្នុងរយៈពេលសាលល្បង ៥ ឆ្នាំ ។

ច-ឈ្មោះ [redacted] រ៉ា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) តែទោសនេះត្រូវព្យួរទាំងអស់ ក្នុងរយៈពេលសាលល្បង ៥ ឆ្នាំ ។

ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌ ដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល និងមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៣-វត្ថុតាងៈ

-ដែកកាត់សោរកម៉ូតូអក្សរ T ទូល្មីស ០១,ញញួរ ០១ ដែកបញ្ចូន ០៣ ដើម,សោរជ្រុងចំនួន ០៨ ដើម ,សោរខ្សៀចំនួន ០៨ ដើម,សោរម៉ាត់ចំនួន ០៦ដើម,ដង្កាប់ចំនួន ០២ ប្រដាប់សម្រាប់ដាប់លេខម៉ូតូចំនួន ០២ ឈុត ហាន ១៨ដើម ត្រូវរឹបអូសហើយបំផ្លាញចោល ។

៤-វត្ថុតាងៈ

-អាវុធខ្លីម៉ាក K ៥៩ លេខ ២០១៦ បង់ ០១ គ្រាប់ ០៧,អាវុធខ្លីម៉ាក K៥៤ គ្រាប់ចំនួន ៣៦ គ្រាប់,ម៉ូតូម៉ាក អ៊ឹមដេត្រៃ ពណ៌ខ្មៅ គ្មានផ្លាកលេខ លេខតួ និងលេខម៉ាស៊ីន ២០១០៧៧៣ គ្មានកុងទ័រ ០១ គ្រឿង និងម៉ូតូម៉ាកហុងដាគ្លីក ពណ៌ក្រហមខ្មៅ ស៊េរី ២០០៧ គ្មានផ្លាកលេខ លេខតួ និងលេខម៉ាស៊ីន ០០១៨៩២៨ គ្មានគុងទ័រ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

៥-ម៉ូតូម៉ាក មីអូ ពណ៌ខ្មៅ ស៊េរី ២០០៤ គ្មានផ្លាកលេខ ហានលេខតួ និងលេខម៉ាស៊ីន ៤៣៧៨៤៣ គ្មានកុងទ័រ ប្រគល់ឱ្យម្ចាស់ដើមវិញ កាលបើគ្មានម្ចាស់មិនឃើញទុកជាសម្បត្តិរដ្ឋ។

-ម៉ូតូ YAMAHA FINO ពណ៌ក្រហម ស៊េរីឆ្នាំ ២០០៨ គ្មានផ្លាកលេខ មានលេខតួ និងលេខម៉ាស៊ីន ០០១៣៥៥ និងរថយន្តម៉ាក Tico ពណ៌ស ហានផ្លាកលេខ ឆ ៧៦៧១ ភព២ ប្រគល់ឱ្យម្ចាស់ដើមវិញ។

៦-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ ឆេង ជាន,ឈ្មោះ [redacted] រ៉ាវី,ឈ្មោះ [redacted] រ៉ាឌី,ឈ្មោះ [redacted] ប៊ុណ្ណារ៉ា ,ឈ្មោះ [redacted] វណ្ណី,ឈ្មោះ [redacted] រ៉ាស្ត និងឈ្មោះ [redacted] ពុទ្ធា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ណារ័ត្ន ,[redacted] រ៉ា និងឈ្មោះ [redacted] ៣៧ និងជនរងគ្រោះ ។

សម្រេចទុកពេលប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រ៉ាវី ប្ដឹងឧទ្ធរណ៍នឹងសាលក្រមលេខៈ ៤៧ (ក្រ.៤) ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០០៨ ត្រង់សេចក្ដីសម្រេចសាលក្រមព្រហ្មទណ្ឌទាំងមូល របស់សាលាដំបូងរាជធានីភ្នំពេញទាំងមូល។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រ៉ាឌី ប្ដឹងឧទ្ធរណ៍នឹងសាលក្រមលេខៈ ៤៧ (ក្រ.៤) ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ ត្រង់សេចក្ដីសម្រេចសាលក្រមព្រហ្មទណ្ឌទាំងមូល របស់សាលាដំបូងរាជធានីភ្នំពេញទាំងមូល។

**បានឃើញ**របាយការណ៍រឿងព្រហ្មទណ្ឌលេខៈ ១០៩០ ចុះថ្ងៃទី ១៧-១២-២០១០ របស់ចៅក្រមនៃសាលាឧទ្ធរណ៍ ។



Scanned with CamScanner

បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ០៦-៥-២០១១ របស់តំណាងមហាអយ្យការអម សាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted]រ៉ាឌី ហៅ ភានាង (វត្តមាន)

-ជនជាប់ចោទឈ្មោះ[redacted]រ៉ាវី (អវត្តមាន)

-មេធាវីការពារលោក [redacted]ពុទ្ធារិទ្ធ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហួន (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]រ៉ាឌី ហៅ ភានាង បានឆ្លើយថាៈ ខ្ញុំមិនសុខចិត្តនិងការផ្តន្ទាទោស រូបខ្ញុំជាអនីតិជន។ វាយកម៉ូតូបងប្អូនវាទៅដាក់បញ្ចាំដាក់ឈ្មោះខ្ញុំ គេឱ្យលុយខ្ញុំ ៥០ ដុល្លាអាមេរិក។ ខ្ញុំជិះម៉ូតូខ្ញុំ ជាមួយឈ្មោះ [redacted] រ៉ាវី ឯកាំភ្លើងជារបស់ឈ្មោះ [redacted] ប៊ុណ្ណារ៉ា ពេលពួកវាទៅវាយប្រតាយជនរងគ្រោះ តែមិនបានម៉ូតូទេ ខ្ញុំអង្គុយនៅលើម៉ូតូមិនបានចូលរួមទេ។ សុំស្រាលទោសបញ្ចូលគ្នា សុំបន្ធូរបន្ថយទោសរូបខ្ញុំ ខ្ញុំសុំកែប្រែខ្លួន។

## សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

សូមតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

មេធាវីការពារលោក [redacted]ពុទ្ធារិទ្ធ បានធ្វើសេចក្តីសន្និដ្ឋានថាៈ អំពើប្រព្រឹត្តរបស់កូនក្តីយោងតាមមាត្រា ៣៥៧ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ សុំបន្ធូរបន្ថយទោសកូនក្តីខ្ញុំ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់។

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រ៉ាវី និងពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted]រ៉ាឌី ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជម្រះ។

២-នៅក្នុងឆ្នាំ ២០០៧ ជនជាប់ចោទឈ្មោះ [redacted] ផាន ឈ្មោះ [redacted] រ៉ាវី,ឈ្មោះ [redacted] ប៊ុណ្ណារ៉ា ហៅ រដ្ឋ និងឈ្មោះ [redacted] រ៉ាឌី បានធ្វើសកម្មភាពប្លន់ម៉ូតូពីជនរងគ្រោះនៅមុំដើមពោធិ៍វិមានឯករាជ្យដោយប្រើកាំភ្លើងម៉ាក K៥៩ ។ ពេលប្លន់ម៉ូតូបាន ជនជាប់ចោទបានយកទៅលក់ ហើយចែកប្រាក់គ្នា។

៣-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] រ៉ាឌី បានឆ្លើយសារភាពនូវអំពើរបស់ខ្លួន គឺពិតជាបានប្លន់ម៉ូតូ ដូចអង្គហេតុដែលបានលើកឡើង ហើយក្រោយមក ១ ខែ ទើបសមត្ថកិច្ចចាប់ខ្លួនបាន សុំឱ្យតុលាការបន្ធូរបន្ថយទោសខ្លួនផង។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទដូចបានចោទប្រកាន់ ប៉ុន្តែជនជាប់ចោទឈ្មោះ[redacted]រ៉ាឌី មានអាយុ ១៧ឆ្នាំ ជាអនីតិជន បានសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន តុលាការនឹងពិចារណាយោងតាមមាត្រា ១០,៣៥៧,១៦០ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៥-តុលាការសាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ បញ្ជាក់អោនលក្ខណ ព្រមៗតាមគតិច្បាប់ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ។ សេចក្តីសម្រេចនៃសាលក្រមលេខៈ ៤៧ ក្រ៤ ចុះថ្ងៃទី ០២-០៥-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ភ៉ាវី និងពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨ របស់ឈ្មោះ វង់ ភ៉ាឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ ក្រ៤ ចុះថ្ងៃទី ០២-០៥-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ ស្តីពីទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ភ៉ាឌី ត្រូវកែប្រែពីដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ មកដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ខែ វិញ។ តាមមាត្រា ១០,១៦០, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមបនីតិវិធី។

-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១១-៦-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២០-៦-២០១២ ដោយសម្រេចសេចក្តី ៖

-ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភ៉ាឌី

-កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ភ៉ាវី ចំពោះមុខមេធាវីការពារ

-បើកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខ តាមកំណត់ច្បាប់។

សាលដីកានេះចូលជាស្ថាពរ មានអនុភាពតែទៅលើឈ្មោះ [redacted] ភ៉ាឌី ប៉ុណ្ណោះ ក្រៅពីនេះពុំទាន់មានអនុភាព អនុវត្តនៅឡើយ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានេះ ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់ដំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

| បានឃើញ | ភ្នំពេញ ថ្ងៃទី០៥ ខែ...៣...... ឆ្នាំ២០១៣ |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |

១៧៣